# ក្រុង LOS ANGELES
# នាយកដ្ឋានលំហែ និងឧទ្យាន (RAP)
## បទបញ្ជាផ្ទៃក្នុងសម្រាប់ការលក់អាហារ និងទំនិញនៅឧទ្យានក្រុង LA

នាយកដ្ឋានលំហែ និងឧទ្យាន (RAP) ជាអង្គភាពគ្រប់គ្រងទៅលើឧទ្យានសាធារណៈចំនួនជាង 450 និងមណ្ឌលលំហែចំនួន 170 កន្លែងវាយកូនហ្គោល ផ្លូវ សារមន្ទីរ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ទីកន្លែងទាំងនេះក៏មានផងដែរនូវកន្លែងសម្រាក កន្លែងក្មេងលេង សួនច្បារសហគមន៍ ចំណតរថយន្ត ទីវាលលេងកីឡា អាងហែលទឹក និងរចនាសម្ព័ន្ធផ្សេងៗទៀត។

អាទិភាពខ្ពស់បំផុតរបស់ RAP គឺថែរក្សាឧទ្យាន វាលលំហ និងហេដ្ឋារចនាសម្ព័ន្ធជាទីតាំងដែលមានសុវត្ថិភាព មានការរៀបចំល្អ និងងាយស្រួលធ្វើដំណើរដើម្បីផ្តល់ភាពសប្បាយរីករាយ និងការកម្សាន្តសម្រាប់ពលរដ្ឋទាំងអស់។ ទោះបីនៅក្នុងទីក្រុង Los Angeles មានការអនុញ្ញាតឱ្យលក់វត្ថុផ្សេងៗនៅក្នុងបរិវេណឧទ្យានក្តី ប៉ុន្តែត្រូវគោរពទៅតាមបទបញ្ជាផ្ទៃក្នុងឱ្យបានខ្ជាប់ខ្ជួនដើម្បីធានានូវអនាម័យ សុវត្ថិភព និងភាពស្អាតជានិច្ច។ បទបញ្ជាផ្ទៃក្នុងទាំងនេះមានរៀបរាប់ដូចខាងក្រោម។

## តើខ្ញុំអាចលក់នៅកន្លែងណាខ្លះក្នុងឧទ្យានទីក្រុង?

ឧទ្យានទាំងអស់នៅក្នុង LA City RAP មិនសុទ្ធតែអាចផ្តល់ទីកន្លែងសម្រាប់អ្នកលក់ដូរដែលមានការអនុញ្ញាតឡើយ។ ប្រសិនបើឧទ្យានមួយមិនហាមឃាត់ដល់អ្នកលក់ដូរទេ នោះអ្នកលក់ដូរអាចលក់នៅលើផ្លូវដើរ ឬកន្លែងថ្មើរជើងដែលបានកំណត់នៅក្នុងឧទ្យាន។

## តើខ្ញុំមិនគួរលក់ដូរនៅកន្លែងណាខ្លះនៅក្នុងឧទ្យានទីក្រុង?

នៅក្នុងស្ថានភាពខ្លះ អ្នកលក់ដូរមិនអាចលក់នៅកន្លែងខាងក្រោមនេះឡើយ៖

- បរិវេណតំហែទាំ ឬរក្សាទុកទំនិញ
- ទីកន្លែងចំណត ឬកន្លែងចតដែលបានកំណត់
- ផ្លូវដី ផ្លូវលំ កន្លែងដាំស្មៅ
- នៅក្នុងចម្ងាយ 100 ហ្វីតពីអគារ មណ្ឌលកម្សាន្ត បន្ទប់ទឹក រចនាសម្ព័ន្ធ ឬកន្លែងក្មេងលេង
- នៅក្នុងចម្ងាយ 500 ហ្វីតពីទីតាំងសាលា ជំរុំ មណ្ឌលសកម្មភាពយុវជន ឬមណ្ឌលមនុស្សចាស់
- នៅក្នុងចម្ងាយ 2500 ពីមហោស្រប Greek Theatre នៅក្នុងពេលរាត្រីដែលមានការប្រគុំតន្ត្រី និងកម្មវិធីផ្សេងៗ
- នៅក្នុងចម្ងាយ 2500 ពី Griffith Observatory ឬចំណត Griffith Observatory

For the complete list of rules and regulations for vending food and commercial items in LA City parks, please visit www.laparks.org/vending.

- ទីតាំងណាមួយពីឧទ្យាន Elysian Park ចាប់ពីរយៈពេលបីម៉ោងមុនចាប់ផ្តើមរហូតដល់បីម៉ោងបន្ទាប់ពីបញ្ចប់រាល់កម្មវិធីទាំងអស់នៅស្តាត Dodger Stadium រួមទាំងកម្មវិធីកីឡា baseball ការប្រគុំតន្ត្រី និងកម្មវិធីប្រណាំងផ្សេងៗ
- ប្រាំ (5) ហ្វីតពីកៅអីឧទ្យាន ឬសង្ហារិមឧទ្យានផ្សេងៗទៀត និងចាប់ពីក្នុងចម្ងាយ 10 ហ្វីតពីគំនូសផ្លូវ ដើរឆ្លង
- ចម្ងាយ 25 ពីស្ទូនបាញ់ទឹក រូបសំណាក វិមាន ឬទីតាំងបង្ហាញវត្ថុសិល្បៈផ្សេងៗ
- ឧទ្យានដែលបានផ្ទេរកម្មសិទ្ធិ ប្រគល់កម្មសិទ្ធិ ឬផ្តល់ជាអំណោយដល់ក្រុង Los Angeles ដែលមានការដាក់បម្រាមចំពោះសកម្មភាពពាណិជ្ជកម្មផ្សេងៗ

## តើខ្ញុំអាចលក់ដូរនៅពេលណា និងយ៉ាងដូចម្តេចនៅក្នុងឧទ្យាក្រុង?

ឧទ្យានរបស់យើងមានម៉ោងអាជីវកម្មធម្មតាដែលពេលខ្លះអាចផ្លាស់ប្តូរពីឧទ្យានមួយទៅឧទ្យានមួយទៀតអាស្រ័យលើការរៀបចំកម្មវិធីនៅទីនោះ ឬការរៀបចំកម្មវិធីពិសេសណាមួយនៅមណ្ឌលកម្សាន្តរបស់យើង។

- អ្នកលក់ដូរត្រូវបិទរយៈពេលយ៉ាងតិច 30 នាទីមុនពេលបិទឧទ្យាន
- ហាមលក់ដូរដាច់ខាតនៅពេលឧទ្យានត្រូវបានបិទ

មានកម្មវិធីពិសេសៗជាច្រើនដែល RAP បានចូលរួម ឬធ្វើជាអ្នករៀបចំកម្មវិធី។ ហាមលក់ដូរនៅពេលថតកុនក្នុងឧទ្យាន កម្មវិធីបុណ្យ កម្មវិធីតន្ត្រី រាត្រីភាពយន្ត កម្មវិធីពិសេស ក្បួនហែរ ព្យុហយាត្រា កម្មវិធីរត់ប្រណាំង និងសកម្មភាពផ្សេងៗទៀតដែលមានការអនុម័ត និងអនុញ្ញាតជាបណ្តោះអាសន្នពីនាយកដ្ឋាន។

## សមត្ថភាព និងលក្ខខណ្ឌផ្សេងៗទៀត

យើងចង់រក្សាឧទ្យានរបស់យើងឱ្យមានសុវត្ថិភាព និងអនាម័យសម្រាប់ភ្ញៀវរបស់យើង និងធានាថាសកម្មភាពលក់ដូរមិនបង្កការរំខានដល់ភាពសប្បាយរីករាយរបស់ភ្ញៀវដែលអញ្ជើញមកឧទ្យានរបស់យើងដើម្បីចូលរួមកម្សាន្ត ឬលំហែ។ ចំនួនអ្នកលក់ដូរក្នុងឧទ្យាននីមួយៗត្រូវបានកំណត់មិនឱ្យមានចំនួនលើសពីពីរ (2) នាក់ក្នុងមួយអ៊ែយើ (acre) នៅក្នុងចម្ងាយ 25 ហ្វីតពីអ្នកលក់ដូរម្នាក់ទៅអ្នកលក់ដូរម្នាក់ទៀត។

ការលក់ដូរនៅក្នុងឧទ្យានត្រូវបានផ្តល់ជូនសម្រាប់អ្នកមុនបានមុន ហើយអ្នកលក់ដូរត្រូវរក្សាទុកបញ្ជីម៉ោងចេញចូលរបស់ខ្លួនឱ្យបានច្បាស់លាស់។

For the complete list of rules and regulations for vending food and commercial items in LA City parks, please visit [www.laparks.org/vending](http://www.laparks.org/vending).

**ក្រុង LOS ANGELES**

**នាយកដ្ឋានលំហែ និងឧទ្យាន** (RAP)

# បទបញ្ជាផ្ទៃក្នុងសម្រាប់ការលក់អាហារ និងទំនិញនៅឧទ្យានក្រុង LA

ខាងក្រោមគឺជាលក្ខខណ្ឌផ្សេងទៀតសម្រាប់អ្នកលក់ដូរ៖

- ត្រូវគោរពតាមនាយកដ្ឋានសុខភាពខោនធី LA (LA County Health Department)។
- ទទួលខុសត្រូវចំពោះការលាងសម្អាត និងការយកចេញនូវកាកសំណល់ អាហារ កញ្ចប់ សំរាម ឬសម្ភារផ្សេងៗដែលកើតឡើងដោយសារ ឬពាក់ព័ន្ធនឹងការលក់ដូររបស់ខ្លួន។
- ហាមដាក់កាកសំណល់រឹងរាវនៅក្នុងធុងសំរាមរបស់ឧទ្យាន រួមទាំងសំណល់ទឹកកកនៅក្នុងបរិវេណឧទ្យានផងដែរ។
- ត្រូវមានប្រដាប់ដាក់សំរាមដែលធន់នឹងសត្វល្អិតចោះស៊ី។
- ហាមភ្ជាប់ជាមួយ ឬប្រើប្រាស់ក្បាលបញ្ចេញទឹក អគ្គិសនី ឬហ្គាសសម្រាប់ការលក់អាហារ ឬទំនិញរបស់ខ្លួន។
- ហាមលក់អាហារ ភេសជ្ជៈ ឬទំនិញដែលគ្មានអនាម័យ ឬគ្មានសុវត្ថិភាព មានគ្រោះថ្នាក់ ឬបង្កផលប៉ះពាល់ចំពោះសុខភាព រួមមានដូចជា សម្ភារៈបាញ់ធ្នូ កាំបិត ចំពាម ឬវត្ថុផ្សេងៗទៀតដែលមានសណ្ឋានជាអាវុធ ដូចជាកាំភ្លើងបាញ់ទឹក កាំភ្លើងជ័រ ឬកាំបិតជ័រជាដើម។
- ត្រូវមាន ឬដាក់បង្ហាញលិខិតអនុញ្ញាតនៅកន្លែងដែលងាយមើលឃើញ។
- គ្មានចំណុចណាមួយនៅក្នុងបទបញ្ជាផ្ទៃក្នុងនេះអនុញ្ញាតឱ្យលក់សេវាផ្ទាល់ខ្លួន ដូចជា ការបង្ហាត់ សេវាម៉ាស្សា យ៉ូហ្គា ការបង្ហាត់សុនខ ការជិះសត្វ សួនលេងជាមួយសត្វ ឬថ្នាក់បង្ហាត់កីឡា/កាយសម្ព័ន្ធផ្សេងៗជាដើម។
- ហាមដាក់ទូ ស្តង់ ឬរទេះរុញលក់ទំនិញឱ្យប៉ះ ផ្អែក ឬភ្ជាប់ជាមួយបង្គោលភ្លើង កន្លែងបង់លុយចំណត ប្រអប់សំបុត្រ ស្លាកសញ្ញាចរាចរណ៍ តុអង្គុយញ៉ាំអាហារ បង្គោលបូមទឹកអគ្គិភ័យ ដើមឈើ រុក្ខជាតិ ប្រអប់ដាំផ្កា កន្លែងដុះថ្ម កៅអីអង្គុយ កន្លែងអង្គុយចាំរថយន្តក្រុង ឬធុងសំរាម។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំរំលោភលើបទបញ្ជាផ្ទៃក្នុងទាំងនេះ?

ការរំលោភទៅលើបទបញ្ជាផ្ទៃក្នុងទាំងនេះនឹងត្រូវរងការពិន័យជាបទល្មើសមិនមែនព្រហ្មទណ្ឌយោងតាមវិធានរដ្ឋបាល Administrative Citation Enforcement (ACE) ស្របតាមច្បាប់ក្រុង Los Angeles Municipal Code ផ្នែក 42.13D។ ច្បាប់ California SB 946 មិនបានហាមឃាត់ RAP មិនឱ្យអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីហាមឃាត់សេវាពាណិជ្ជកម្មដែលគ្មានការអនុញ្ញាតនៅតាមឧទ្យានឡើយ។ នាយកដ្ឋានលំហែ និងឧទ្យានសូមរក្សាសិទ្ធិក្នុងការកែប្រែ ឬផ្លាស់ប្តូរផ្នែកណាមួយនៃបទបញ្ជាផ្ទៃក្នុងនេះស្របទៅតាមច្បាប់ក្នុងមូលដ្ឋាន និងច្បាប់រដ្ឋនៅពេលណាមួយ និងទៅតាមការចាំបាច់។